# ចាស់ផ្លែស្តុកស្តោ[1]

១. ចាស់មិនស្តាប់ក្មេង រមែងអួត ពេញដោយអំណួត កប់អាត្មា
អាងថាខ្លួនចាស់ ចេះសព្វការ ពេញដោយប្រាជ្ញា ជាឧឡារ ។

២. ចាស់មិនស្តាប់ក្មេង រមែងលោត ខឹងខុសច្រឡោត មិនពិចារ
យកវ័យចំណាស់ ខ្វះមេត្តា អោយក្មេងត្រាប់ការ ទាំងគិតខ្ចី ។

៣. បើចាស់ពូកែ ខ្មែរមិនធ្លាក់ ចូលជ្រុះមរណៈ ដូចរាល់ថ្ងៃ
គឺចាស់ជាអ្នក នាំចង្រៃ នាំគ្រោះទុក្ខភ័យ អោយជាតិខ្លួន ។

៤. បើចាស់ពូកែ ខ្មែរនឹងល្បី មិនមែនបាត់ដី បង់អស់ក្បួន
ចាញ់ចោរសាត់ព្រាត់ ធុនសៀមយួន រួចឆ្លើយដោះខ្លួន មិនព្រមខុស ។

៥. ចាស់ប្រុសចូលចិត្ត តែក្មេងស្រី ហ្នឹងអាលលកលៃ ដឹកឡើងចុះ
យកប្រាក់ដុល្លា ទាក់ច្រមុះ បើស្មានមិនខុស ព្រោះចង់ប្រាណ ។

៦. ចាស់ស្រីស៊ីជោរ ងរខុសក្បួន ចូលចិត្តធ្វើខ្លួន ដឹងហួសដាន
បើបានគេលើក ថ្កើងអោយថ្កាន ស៊ីជោរហួសស្មាន ដែនកំណើត ។

៧. ចាស់ធុននេះហៅ ថាចាស់ព្រើល មិនចេះប្រមើល មើលលិចកើត
វង្វេងវនោច ថាជាខ្មើត ខ្លួនចាស់មិនកើត បន្ទោសក្មេង ។

៨. បើក្មេងធ្វើខុស ព្រោះទ្រឹស្តី គង់ចេះលកលៃ គិតស្តាំឆ្វេង
ព្រោះវិទ្យាសាស្ត្រ ច្បាស់គឺក្មេង មិនមែនចាស់ឆ្វេង ខុសមិនកែ ។

៩. កំណាព្យកំណប់ បង្កប់ន័យ សូមចាស់ប្រណៃ កុំដូចឆ្កែ
ប្រឡោតលោតខឹង ព្រោះសំណេរ សូមគិតរិះរេ ចាស់មួយណា..........?

**ដោយៈ ដែនដីសេរីភាព**

---

[1] *ផ្លែស្តុកស្តោ ពេលចាស់ ឬ ទុំ មានរស់ជាតិផ្អែមណាស់ តែមិនអាចឆីបានច្រើនលើសពី ៣-៤ ផ្លែទេ ព្រោះវាកាត់អណ្តាតយើងរហូតដាច់ចេញឈាម ។*